**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation Religion King

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**
Ministry of Industry, Science, Technology & Innovation

លេខៈ ១៧០ ឧវិបន.មបជ.សជណ.......

# សេចក្តីជូនដំណឹង
## ស្តីពី
## ការត្រួតពិនិត្យផ្ទៀងផ្ទាត់ជញ្ជីងថ្លឹងរថយន្តសម្រាប់ឆ្នាំ២០២៤

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី ជាម្ចាស់ជញ្ជីងថ្លឹងរថយន្ត ដែលកំពុងធ្វើអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជាទាំងអស់ ឱ្យបានជ្រាបថាៈ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ជាអង្គភាពជំនាញនឹងបន្តអនុវត្តការត្រួតពិនិត្យផ្ទៀងផ្ទាត់សម្រាប់ឆ្នាំ២០២៤ ទៅលើសុក្រឹតភាពជញ្ជីងថ្លឹងរថយន្តដែលធ្វើពាណិជ្ជកម្មលើកដំបូងចំពោះជញ្ជីងថ្មី ឬ ជញ្ជីងដែលត្រូវបានជួសជុលរួច និង ជញ្ជីងដែលត្រូវបានត្រួតពិនិត្យផ្ទៀងផ្ទាត់រួច និងបាននឹងកំពុងត្រូវប្រើប្រាស់ ហើយនឹងផុតសុពលភាពក្នុងអំឡុងឆ្នាំ២០២៤។ ការត្រួតពិនិត្យផ្ទៀងផ្ទាត់នេះនឹងបង្កើនទំនុកចិត្តរវាងម្ចាស់ជញ្ជីង និងអ្នកប្រើប្រាស់ជញ្ជីងទាំងអស់។

ចំពោះជញ្ជីងថ្លឹងរថយន្តទាំងឡាយណា ដែលមិនមានការត្រួតពិនិត្យផ្ទៀងផ្ទាត់ និងដាក់ស្លាកសញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នឹងចាត់វិធានការតាមច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា ដូចមានចែងក្នុងជំពូកទី១០ ស្តីពីទោសប្បញ្ញត្តិជាកំហិត។

អាស្រ័យហេតុនេះ សូម ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី ជាម្ចាស់ជញ្ជីងថ្លឹងរថយន្តទាំងអស់ សហការអនុវត្តកិច្ចការត្រួតពិនិត្យផ្ទៀងផ្ទាត់តាមសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ស្របតាមច្បាប់ និងលិខិតបទដ្ឋាននានាដែលបានកំណត់។ សូម ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី ឬតំណាង មកទំនាក់ទំនងផ្ទាល់នៅការិយាល័យច្រកចេញចូលតែមួយរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលមានទីតាំងនៅមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឬតាមរយៈលេខទូរសព្ទ និងតេឡេក្រាម ៖ **០៩៧ ៩៧០ ២០៥៥** និងអ៊ីម៉ែលៈ **owsnmc.misti@yahoo.com** ចាប់ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ (នៅរៀងរាល់ម៉ោងធ្វើការ) ដើម្បីរៀបចំសំណុំឯកសារស្នើសុំត្រួតពិនិត្យផ្ទៀងផ្ទាត់ជញ្ជីងថ្លឹងរថយន្តរបស់ ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី ហើយត្រូវបង្កលក្ខណៈងាយស្រួលដល់ការបំពេញភារកិច្ចរបស់មន្ត្រីត្រួតពិនិត្យ និងលក្ខខណ្ឌតម្រូវនានាដែលពាក់ព័ន្ធនឹងបច្ចេកទេស។

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សង្ឃឹម និងជឿជាក់ថា ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី ជាម្ចាស់ជញ្ជីងថ្លឹងរថយន្តទាំងអស់នឹងយកចិត្តទុកដាក់ និងសហការអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាព ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ សុក្រ ១រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែមករា ឆ្នាំ២០២៤
**រដ្ឋមន្ត្រី**

**ហែម វណ្ណឌី**

**ចម្លងជូនៈ**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
  "ដើម្បីគោរពជូនជ្រាប"
- រដ្ឋបាលរាជធានី-ខេត្ត
  "ដើម្បីសហការអនុវត្ត"
- គ្រប់មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានី-ខេត្ត
  "ដើម្បីផ្សព្វផ្សាយបន្ត និងសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ